#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ជំពូកទី១ៈ
សេចក្តីផ្តើម

Draft

ជំពូកទី១ ៖ សេចក្តីផ្តើម

១.១ លក្ខណៈទូទៅនៃគម្រោង

ប្រទេសកម្ពុជាកំពុងចូលរួមអនុវត្តន៍គម្រោងអូសខ្សែកាប្ល៍អុបទិច ក្រោមបាតសមុទ្របន្តពីសមុទ្រប្រទេសម៉ាឡេស៊ី ដែលអូសកាត់សមុទ្រកម្ពុជាខេត្តព្រះសីហនុ និងបន្តរហូតដល់ប្រទេសថៃ។ គម្រោងនេះ មានចក្ខុវិស័យ ចូលរួមពង្រឹង និងបំពេញលើតម្រូវការខ្វះខាតនៃការប្រើប្រាស់ប្រព័ន្ធចែកចាយព័ត៌មាន ប្រព័ន្ធទូរស័ព្ទ ប្រព័ន្ធអ៊ីនធឺណែត និងប្រព័ន្ធទូរគមនាគមន៍ ទាំងក្នុងនិងក្រៅប្រទេស ឱ្យបានទូលំទូលាយ និងកាន់តែលឿនរហ័សជាងមុន។ ការវិនិយោគលើគម្រោងខ្សែកាប្ល៍អុបទិចនេះ គឺស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលដែលមានចក្ខុវិស័យទៅលើការអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ ឱ្យមានប្រសិទ្ធិភាពខ្ពស់ និងចែកចាយព័ត៌មានឱ្យមានប្រសិទ្ធិភាព និងគ្របបដណ្តប់ទូទាំងប្រទេស។ ចក្ខុវិស័យនេះ តម្រូវឱ្យមានការវិនិយោគដ៏ធំសម្បើមមួយ ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធដ៏រឹងមាំលើប្រព័ន្ធទូរគមនាគមន៍ពិសេសខ្សែកាប្ល៍អុបទិច ដែលមានល្បឿនលឿនសម្រាប់ការអភិវឌ្ឍន៍នៃប្រព័ន្ធទូរគមនាគមន៍កម្ពុជា។ ខ្សែកាប្ល៍អុបទិចនេះ ត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយថាជាគន្លឹះយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច។ គម្រោងតភ្ជាញ់ខ្សែកាប្ល៍អុកទិចក្រោមបាតសមុទ្រនេះ ត្រូវបានសហការណ៍ដោយក្រុមហ៊ុនចំនួន០៣គឺ ក្រុមហ៊ុន Telekom Malaysia Berhad Co., Ltd របស់ប្រទេសម៉ាលេស៊ី ក្រុមហ៊ុន Symphony Communication Public Co.,Ltd របស់ប្រទេសថៃ និងក្រុមហ៊ុន Telcotech Ltd (EZECOM) របស់ប្រទេសកម្ពុជា។ ប្រព័ន្ធខ្សែកាប្ល៍អុបទិកម៉ាលេស៊ី-កម្ពុជា-ថៃ (MCT) នឹងត្រូវបានតភ្ជាប់ និងតម្លើងស្ថានីយ៍ខ្សែកាប្ល៍នៅតាមប្រទេសនីមួយៗ។ សម្រាប់ប្រទេសកម្ពុជានឹងធ្វើការសាងសង់ស្ថានីយ៍ខ្សែកាប្ល៍ នៅខេត្តព្រះសីហនុ ដែលគម្រោងនេះនឹងអាចជួយបង្កើនសេវាអ៊ីនធឺណែតលឿនរហ័ស និងមានតម្លៃទាប។

១.២ ទស្សនៈវិស័យ និងគោលបំណងនៃគម្រោងអភិវឌ្ឍន៍

គោលបំណងសំខាន់របស់គម្រោងបង្កប់ខ្សែកាប្ល៍អុបទិចក្រោមបាតសមុទ្រទាំង៣ប្រទេស (MCT) គឺដើម្បីជួយលើកស្ទួយវិស័យទូរគមនាគមន៍ និងទំនាក់ទំនងក្នុងសមាហរណកម្ម ASEAN ដ៏ខ្លីខាងមុខនេះ។ នៅបណ្តាប្រទេសដែលជាសមាជិក ASEAN ទាំងអស់សុទ្ធតែមានកប់ខ្សែកាប្ល៍ក្រោមបាតសមុទ្ររួចហើយ លើកលែងតែប្រទេសឡាវ ដែលមិនមានព្រំដែនជាប់សមុទ្រ ប៉ុន្តែប្រទេសនេះធ្វើការទំនាក់ទំនងទូរគមនាគមន៍ទៅបណ្តាប្រទេសដទៃតាមរយៈដីគោកវិញ។ សម្រាប់

Draft

ប្រទេសកម្ពុជា ការតម្លើងខ្សែកាប្ល៍អុបទិចក្រោមបាតសមុទ្រ នឹងផ្តល់នូវសមត្ថភាពខ្ពស់ក្នុងការតភ្ជាប់បណ្តាញប្រព័ន្ធបច្ចេកវិទ្យា និងទូរគមនាគមន៍ ក្នុងប្រទេស ដើម្បីបម្រើដល់សេវាកម្មផ្សេងៗ និងជួយពង្រឹង និងការអភិវឌ្ឍន៍ រវាងប្រទេសកម្ពុជា ប្រទេសម៉ាឡេស៊ី និងប្រទេសថៃ។ គម្រោងនេះ បានប្រមើលឃើញលើទស្សនៈវិស័យខ្ពស់លើប្រព័ន្ធទំនាក់ទំនងមួយដែលមានប្រសិទ្ធិភាព ធ្វើឡើងដោយមានគុណភាពខ្ពស់ និងមានទំនុកចិត្តពីសំណាក់ប្រជាជនទាំងមូល។ ការដាក់ទុនវិនិយោគ លើគម្រោងអភិវឌ្ឍន៍បណ្តាញខ្សែកាប្ល៍អុបទិចក្រោមបាតសមុទ្រ នៃប្រទេសកម្ពុជាមានគោលបំណងសំខាន់ធំៗចំនួនបីគឺ (ទី១) ដើម្បីចូលរួមចំណែកអភិវឌ្ឍលើវិស័យបច្ចេកវិទ្យា និងទូរគមនាគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការប្រើប្រាស់ប្រព័ន្ធទូរស័ព្ទ អ៊ីនធឺណេត និងបណ្តាញខ្សែកាប្ល៍ផ្សេងៗ (ទី២) ដើម្បីជួយលើកស្ទួយសេដ្ឋកិច្ចជាតិ តាមរយៈការបង់ពន្ធវិនិយោគ និងពន្ធពីអ្នកប្រើប្រាស់ និង (ទី៣) ដើម្បីរួមចំណែកលើកស្ទួយសេដ្ឋកិច្ចគ្រួសារតាមរយៈការផ្តល់សេវាកម្មប្រើប្រាស់ដែលមានតម្លៃថោកសមរម្ស។

គម្រោងបង្កប់ខ្សែកាប្ល៍អុបទិចក្រោមបាតសមុទ្រទាំងបីប្រទេស (MCT) មានប្រវែងសរុបចំនួន **១.៣៨០គីឡូម៉ែត្រ** ឆ្លងកាត់បីប្រទេសដែលនៅជាប់ឈូងសមុទ្រថៃ គឺប្រទេសម៉ាឡេស៊ី កម្ពុជា និង ថៃ ហើយមានក្រុមហ៊ុនចំនួន៣ ទទួលខុសត្រូវលើការអភិវឌ្ឍន៍តាមប្រទេសនីមួយៗ។ **ទី១) ក្រុមហ៊ុន** Telekom Malaysia Berhad Co.,Ltd (ប្រទេសម៉ាឡេស៊ី) **ទី២) ក្រុមហ៊ុន** Telcotech Ltd (ប្រទេសកម្ពុជា) និង**ទី៣) ក្រុមហ៊ុន** Symphony Communication Public Co.,Ltd (ប្រទេសថៃ)។ ប្រទេសម៉ាឡេស៊ី ជាទីតាំងតំណខ្សែកាប្ល៍មួយនៃប្រព័ន្ធខ្សែកាប្ល៍របស់អាមេរិច (AAG) (ប្រវែង **២0.000 គីឡូម៉ែត្រ**) ដែលភ្ជាប់ពីឆ្នេរអាមេរិចខាងលិចជាមួយនឹងអាស៊ីបូព៌ា។

សម្រាប់ប្រទេសកម្ពុជា ក្រុមហ៊ុន Telcotech Ltd ដែលជាផ្នែកមួយរបស់ក្រុមហ៊ុន Royal Group បានទទួលសិទ្ធិវិនិយោគសាងសង់ស្ថានីយ៍ខ្សែកាប្ល៍ និងបង្កប់ខ្សែកាប្ល៍អុបទិច ដែលកាត់តាមដែនសមុទ្រកម្ពុជាមានប្រវែងសរុប **៤៧0គីឡូម៉ែត្រ** ដែលគេហៅថា **គម្រោងបង្កប់ខ្សែកាប្ល៍អុបទិចក្រោមបាតសមុទ្រកម្ពុជា**។ ទោះជាយ៉ាងណាក៏ដោយ វិធីដែលល្អបំផុតសម្រាប់ការសាងសង់បណ្តាញ ការតម្លើង និងការថែទាំ គឺយើងត្រូវគិតទៅលើហេតុប៉ះពាល់សំខាន់ៗ ដូចជា ស្ថានភាពបរិស្ថានបាតសមុទ្រ ព្រំដែនអន្តរជាតិ និងស្ថានភាពសង្គម-សេដ្ឋកិច្ច។ ដើម្បីឱ្យគម្រោងវិនិយោគនេះ ទទួលបានជោគជ័យទាមទារឱ្យមានការរៀបចំ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ និងផែនការគ្រប់គ្រងបរិស្ថាន ដោយមានការទទួលស្គាល់ពីក្រសួងបរិស្ថាន។ ការរៀបចំរបាយការណ៍នេះ ដើម្បីកំណត់នូវហេតុប៉ះពាល់ដែលកើតមានឡើងនៅក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង នឹងចាត់វិធានការកាត់បន្ថយនូវហេតុប៉ះពាល់ទាំងនោះ ឱ្យស្ថិតនៅក្នុងកម្រិតអប្បរមា។

១.៣ ទំហំនៃគម្រោង

ខ្សែកាប្ល៍អុបទិចក្រោមបាតសមុទ្រទាំង៣ប្រទេសមានប្រវែងសរុបប្រមាណជា **១.៣៨០ គីឡូម៉ែត្រ** ដែលភ្ជាប់ពីប្រទេសម៉ាឡេស៊ីមានប្រវែង **៧៦៤គីឡូម៉ែត្រ** កាត់សមុទ្រប្រទេសកម្ពុជាប្រវែងប្រហែល **៤៧០គីឡូម៉ែត្រ** ហើយភ្ជាប់ពីដែនសមុទ្រកម្ពុជា ទៅកាន់ដែនសមុទ្រថៃមានប្រវែង **១៤៦គីឡូម៉ែត្រ**។ សម្រាប់គម្រោងបង្កប់ខ្សែកាប្ល៍អុបទិច កាត់តាមដែនសមុទ្រកម្ពុជា ដែលមានប្រវែងសរុប **៤៧០គីឡូម៉ែត្រ** គឺមានបីខ្នែង ដែលខ្នែងទី១ជាខ្សែដែលចាប់ពីព្រំប្រទល់សមុទ្រកម្ពុជា មកចំណុចតំណរភ្ជាប់ (Brandching Unit, BU) ដែលមានប្រវែង **២៥២គីឡូម៉ែត្រ** ខ្នែងទី២ គឺចាប់ពីចំណុចតំណរភ្ជាប់(BU) មកកាន់ឆ្នេរអូរត្រេះ នៃក្រុងព្រះសីហនុ មានប្រវែង **៥៥គីឡូម៉ែត្រ** និងខ្នែងទី៣ ចាប់ពីចំណុចតំណរភ្ជាប់ (BU) ទៅខេត្តរ៉ាក់យ៉ងប្រទេសថៃមានប្រវែងសរុប **១៥៣ គីឡូម៉ែត្រ**។

គម្រោងនេះ បានចាប់ផ្តើមដំណើរការសាងសង់ស្ថានីយ៍ខ្សែកាប្ល៍នៅចុងឆ្នាំ២០១៥ គ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០១៦ ដែលបច្ចុប្បន្ន ក្រុមហ៊ុនសាងសង់បានប្រហែល៨០%។ បន្ទាប់ពីសាងសង់ស្ថានីយ៍ខ្សែកាប្ល៍រួច ក្រុមហ៊ុននឹងបង្កប់ខ្សែកាប្ល៍ទៅតាមផែនការមេ ដែលគ្រោងនឹងបង្កប់នៅដើមឆ្នាំ២០១៦ បញ្ចប់ដាក់ឲ្យដំណើរការនៅដើមឆ្នាំ២០១៧។ គម្រោងនេះមានទុនវិនិយោគសរុបប្រមាណជា **២១លានដុល្លារសហរដ្ឋអាមេរិក** សម្រាប់ការបង្កប់ខ្សែកាប្ល៍នៃប្រទេសកម្ពុជា។ គោលបំណងនៃគម្រោងនេះ គឺធ្វើឱ្យប្រសើរឡើង នូវការចែកចាយបណ្តាញសេវាកម្មទំនាក់ទំនង និងផ្តល់ជូននូវសេវាអ៊ីនធឺណេតដែលមានល្បឿនលឿន សម្រាប់ជាមូលដ្ឋានគ្រឹះបច្ចេកវិទ្យា ក្នុងវិស័យទូរគមនាគមន៍របស់ប្រទេសកម្ពុជា។ លើសពីនេះ គម្រោងអាចជួយពន្លឿនដល់ការទំនាក់ទំនង ការបញ្ជូនឯកសារ និងទិន្នន័យទៅវិញទៅមកនៅក្នុងស្ថាប័នរដ្ឋាភិបាល ក្រសួង អង្គការ វិស័យឯកជន និងប្រជាជន កម្ពុជាទាំងមូលឱ្យមានភាពប្រសើរជាងមុន។

១.៤ សេចក្តីផ្លែងបញ្ជាក់នៃគម្រោង

នៅក្នុងអាណត្តិទី៥ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រទេសកម្ពុជាមានការអភិវឌ្ឍន៍ និងវិវឌ្ឍន៍ជាលំដាប់ទៅលើគ្រប់វិស័យ។ ខេត្តព្រះសីហនុ ជាប៉ូលសេដ្ឋកិច្ចដ៏ខ្លាំងមួយ ដែលមានសក្តានុពលខាងផ្នែកដឹកជញ្ជូន ឧស្សាហកម្ម ពាណិជ្ជកម្ម និងពិសេសផ្នែកទេសចរណ៍។ ដោយសារតែខេត្តមួយនេះជាប់សមុទ្រ ហើយសំបូរទៅដោយកោះ និងធនធានធម្មជាតិជាច្រើនទាំងនៅលើគោក និងក្នុងសមុទ្រ ព្រមទាំងខេត្តព្រះសីហនុជាផ្លូវដឹកជញ្ជូនដ៏សំខាន់ទៅកាន់បណ្តាប្រទេសក្នុងតំបន់ ASEAN និងអន្តរជាតិ និងកត្តាអំណោយផលពីទីតាំងភូមិសាស្ត្រ គោលនយោបាយរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងផ្លូវដែក ដែលបានតភ្ជាប់ទៅកាន់រាជធានីភ្នំពេញ និងបណ្តាខេត្ត

ផ្សេងៗទៀត ធ្វើឱ្យខេត្តមួយនេះទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសមកលើខេត្តនេះ។

ដោយមើលឃើញពីភាពខ្វះខាត ព្រមទាំងតម្រូវការប្រើប្រាស់ប្រព័ន្ធទូគមនាគមន៍ ជាពិសេសប្រព័ន្ធអ៊ីនធឺណែតក្នុងប្រទេសកម្ពុជាបានកើនឡើងយ៉ាងខ្លាំង គួបផ្សំជាមួយគោលនយោបាយបើកទូលាយរបស់រាជរដ្ឋាភិបាលលើការអភិវឌ្ឍន៍វិស័យនេះ ទើបមានក្រុមហ៊ុន **Telcotech Ltd** (ប្រទេសកម្ពុជា) បានដាក់ទុនវិនិយោគលើគម្រោងខ្សែកាប្ល៊ីអុបទិចបង្កប់ក្រោមបាតសមុទ្រកម្ពុជា ដែលអូសចេញពីប្រទេសម៉ាឡេស៊ី កាត់ឈូងសមុទ្រថៃចូលមកប្រទេសកម្ពុជាមានប្រវែងសរុប**៤៧០គីឡូម៉ែត្រ**។

លើសពីនេះទៅទៀតការវិនិយោគលើគម្រោង ខ្សែកាប្ល៊ីអុបទិចបង្កប់ក្រោមបាតសមុទ្រ គឺផ្អែកទៅលើទស្សនៈវិស័យនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដោយធានាឲ្យបាននូវការអភិរក្សបរិស្ថានធម្មជាតិ ដែលមានស្រាប់រួមទាំងការចូលរួមថែរក្សា ការពារ និងការធ្វើឱ្យកាន់តែប្រសើរឡើងថែមទៀតនូវធនធានធម្មជាតិដែលរេចរឹលតាមរយៈផ្តល់មូលនិធិបរិស្ថាន-សង្គម។ ដូច្នេះដើម្បីសម្រេចឲ្យបាននូវទស្សនៈវិស័យលើការអភិវឌ្ឍនេះ តម្រូវឲ្យមានការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញជាមុន (Environmental and Social Impact Assessment) ដើម្បីបង្ហាញពីហេតុប៉ះពាល់ជាវិជ្ជមាន និងបញ្ចៀសនូវហេតុប៉ះពាល់អវិជ្ជមានរបស់គម្រោងព្រមទាំងការផ្តល់នូវអនុសាសន៍ជូនដល់រាជរដ្ឋាភិបាល និងម្ចាស់គម្រោង ហើយធ្វើការផ្សព្វផ្សាយដល់សាធារណៈជនឲ្យបានដឹងលឹមជ្រៅ។ ការវាយតំលៃនេះត្រូវបានរៀបចំឡើងដោយក្រុមហ៊ុន **ក្រីអេធីវ ហ្គ្រីន ឌីហ្សាញ** (Creative Green Design Co., Ltd (CGD) ដោយសហការជាមួយម្ចាស់គម្រោងអភិវឌ្ឍន៍ក្រុមហ៊ុន **តែលកូថេក** (**Telcotech Ltd**) ក្រោមការត្រួតពិនិត្យយ៉ាងត្រឹមត្រូវពីក្រសួងបរិស្ថាន និងបណ្តាក្រសួង និងស្ថាប័នដែលពាក់ព័ន្ធមួយចំនួន។ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញលើគម្រោងអភិវឌ្ឍន៍ **ខ្សែកាប្ល៊ីអុបទិចបង្កប់ក្រោមបាតសមុទ្រ** នេះនឹងបានបញ្ជាក់ពីចរភាពនៃការអភិវឌ្ឍនៅពេលកំពុងសាងសង់គម្រោង និងក្រោយពេលសាងសង់គម្រោង។

១.៥ គោលបំណងនៃការសិក្សា

ការសិក្សានេះមានគោលបំណងដូចខាងក្រោមគឺ៖

- សិក្សាទៅលើលក្ខណៈបច្ចេកទេសក្នុងការតភ្ជាប់ខ្សែកាប្ល៊ី និងវិធីសាស្ត្រក្នុងការបង្កប់ ខ្សែកាប្ល៊ីអុបទិចក្រោមបាតសមុទ្រ
- សិក្សាពីធនធានរូបសាស្ត្រនៃគម្រោងខ្សែកាប្ល៊ីអុបទិច (លក្ខណៈអាកាសធាតុ ជលសាស្ត្រ ស្រទាប់ដីក្រោមបាតសមុទ្រជាដើម)។

- សិក្សាពីធនធានជីវៈសាស្ត្រនៃគម្រោងខ្សែកាប្ល៊ីអុបទិច (ផ្ការ៉ូ និងត្រី....។ល។)។
- វិភាគលើផលចំណេញសេដ្ឋកិច្ច និងការខូចខាតបរិស្ថានរបស់គម្រោងខ្សែកាប្ល៊ីអុកទិច
- កំណត់ហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ កំណត់វិធានការកាត់បន្ថយ និងរៀបចំផែនការគ្រប់គ្រងបរិស្ថាន។
- ពិគ្រោះយោបល់ជាមួយស្ថាប័នដែលពាក់ព័ន្ធ ធ្វើការផ្សព្វផ្សាយអំពីគម្រោង។
- រៀបចំមូលនិធិបរិស្ថាន និងសង្គម ដើម្បីស្តារ និងធ្វើឲ្យបរិស្ថានធម្មជាតិ និងសង្គមប្រសើរ។

១.៦ ទាក់ទិការសង្ខេប

១. សេចក្តីផ្តើម
២. វិធីសាស្ត្រសិក្សាស្រាវជ្រាវ
៣. ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ
៤. ការពិពណ៌នាអំពីគម្រោងអភិវឌ្ឍន៍
៥. ការពិពណ៌នាអំពីធនធានបរិស្ថានដែលមានស្រាប់
៦. ការចូលរួមពីសាធារណៈ និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ
៧. ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ
៨. ផែនការគ្រប់គ្រងបរិស្ថាន
៩. ការវិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថាន
១០. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

Draft